# សេចក្តីថ្លែងការណ៍រួម

## ធានា សមភាពរវាងស្ត្រី និងបុរសក្នុងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ក្នុងពេលដែលអគ្គលេខាធិការដ្ឋានរដ្ឋសភាជាតិកំពុងទទួលពាក្យបេក្ខជន និងបេក្ខនារីសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) តាងនាមគណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ បណ្តុំស្ត្រីកម្ពុជា បណ្តាញយេនឌ័រ និងអភិវឌ្ឍន៍ បណ្តាញបុរសកម្ពុជា និងអង្គការសង្គមស៊ីវិលស្ត្រី ដែលធ្វើការលើសិទ្ធិស្ត្រី ស្នើសុំឲ្យមានវិធានការជ្រើសរើសសមាជិក ឲ្យមានសមភាពរវាងបុរស និងស្ត្រី។

ក្រុមការងារស្ត្រី ឃើញថាសមភាពយេនឌ័រ គឺជាវិធានការផ្តល់នូវយុត្តិធម៌សង្គម និងការអភិវឌ្ឍប្រកបដោយចីរភាព។ ហេតុដូច្នេះហើយ រាជរដ្ឋាភិបាលបានលើកឡើង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងនារីរតនៈទី៤ បានទទួលស្គាល់ និងលើកឡើងពីសារៈសំខាន់នៅក្នុងតួនាទីសម្រេចចិត្ត ក្នុងវិស័យនយោបាយ និងមុខងារសាធារណៈ។ ការខ្វះខាតវិធានការពិសេសក្នុងប្រទេសកម្ពុជាកន្លងមក គឺជាឧបសគ្គចំបងរារាំងដល់ការបង្កើនចំនួនស្ត្រី ដែលមានចំនួន៥២% នៃប្រជាពលរដ្ឋកម្ពុជាក្នុងតួនាទីធ្វើសេចក្តីសម្រេច និងមុខងារសាធារណៈ។ ជាមួយគ្នានេះដែរ មាត្រា ៣ នៃអនុសញ្ញាស៊ីដ បានចែងថា "គ្រប់វិស័យ ជាពិសេសវិស័យនយោបាយ សង្គមកិច្ច សេដ្ឋកិច្ច និងវប្បធម៌ រដ្ឋត្រូវចាត់វិធានការសមស្របទាំងអស់ រួមមានការធ្វើច្បាប់ផង ដើម្បីធានាការអភិវឌ្ឍ និងការរីកចម្រើនពេញលេញរបស់ស្ត្រី ដើម្បីធានាឲ្យស្ត្រីប្រើប្រាស់ និងអាស្រ័យផលសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន ដោយសមភាពជាមួយបុរស"។ បន្ថែមពីលើនេះទៀត គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់ពិភពលោកក៏បានលើកនូវគោលដៅ សមភាពយេនឌ័រ ៥០%លើ៥០% នៅឆ្នាំ២០៣០។ ទន្ទឹមនឹងនេះ សេចក្តីថ្លែងការណ៍ផែនការសកម្មភាពទីក្រុងប៉េកាំង+២០ អាស៊ីប៉ាស៊ីហ្វិក ក៏បានលើកឡើងនៅក្នុងផ្នែកបុព្វកថា ត្រង់កថាខ័ណ្ឌទី២ "....ការលើកតម្កើងស្ត្រី និងការសម្រេចឲ្យបាននូវសមភាពរវាងស្ត្រី និងបុរសគឺជាបញ្ហាសិទ្ធិមនុស្ស និងជាលក្ខខណ្ឌមួយ នៃយុត្តិធម៌សង្គមដូច្នេះមិនគួរត្រូវបានចាត់ថាត្រឹមតែជាបញ្ហារបស់ស្ត្រីនោះទេ....." បន្ថែមលើនេះទៀត "....ការផ្តល់ ភាពអង់អាចដល់ស្ត្រី និងក្មេងស្រីគឺជាបុរេលក្ខខណ្ឌដើម្បីសម្រេចឲ្យបាននូវការអភិវឌ្ឍសង្គមសេដ្ឋកិច្ចប្រកបដោយនិរន្តរភាពសម្រាប់ទាំងអស់គ្នា និងយុត្តិធម៌នៅក្នុងសង្គម..."។

អង្គការសង្គមស៊ីវិល និងបណ្តាញស្ត្រីស្នើដល់គណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភាជាតិ និងតំណាងរាស្ត្រនៃគណបក្សទាំងពីរត្រូវធានាឲ្យបានសមភាពរវាងបុរស និងស្ត្រីក្នុង គ.ជ.ប ដោយសូមដាក់ជូននូវអនុសាសន៍ដូចខាងក្រោមនេះ ៖

១. បើប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជាស្ត្រី ឬបុរស អនុប្រធានត្រូវតែជាភេទផ្ទុយ។

២.សមាជិក ៤ រូប នៃគ.ជ.ប ដែលជ្រើសរើសដោយគណបក្សនយោបាយនីមួយៗ ត្រូវតែមានស្ត្រីយ៉ាងតិច ១រូប ទៅ២រូប។

អង្គការសង្គមស៊ីវិល និងបណ្តាញស្ត្រីយើងខ្ញុំ ត្រៀមខ្លួនជានិច្ចដើម្បីធ្វើការសហការក្នុងការជំរុញកិច្ចការងារនេះឲ្យបានជោគជ័យ។

ភ្នំពេញ ថ្ងៃទី ៣១ ខែមិនា ឆ្នាំ២០១៥

ទំនាក់ទំនងព័ត៌មានបន្ថែម៖

-លោកស្រី ធីតា យិះ នាយិកាប្រតិបត្តិអង្គការសីលការ និងជាប្រធានគណៈកម្មាធិការលើកស្ទួយស្ត្រីក្នុងវិស័យនយោបាយ ០១២ ៨៣៨ ៩៦៤

-លោក ឆាយ គីមស័រ អ្នកសម្របបណ្តាញបុរសកម្ពុជា នៃអង្គការយេនឌ័រ និងអភិវឌ្ឍន៍នៅកម្ពុជា ០១២ ៦២៧ ៨៣៧៣.